# វ៉ាក់សាំងជំងឺ COVID-19៖ ការពិតដែលអ្នកត្រូវដឹង

ct.gov/covidvaccine

Keeping Connecticut Healthy
DPH
Connecticut Department of Public Health

## ការពិតទី #1

### វ៉ាក់សាំងជំងឺ COVID-19 នឹងមិនធ្វើឲ្យអ្នកកើតជំងឺ COVID-19 ទេ។

វ៉ាក់សាំងជំងឺ COVID-19 មិនមានផ្ទុកនូវចំណែកណាមួយនៃវីរុស និងមិនអាចបង្កឲ្យឆ្លងជំងឺ ឬលទ្ធផលវិជ្ជមាននៅលើតេស្តរោគវិនិច្ឆ័យនោះទេ។

## ការពិតទី #2

### ការផលិតវ៉ាក់សាំងជំងឺ COVID-19 បានយ៉ាងឆាប់រហ័ស មិនមានន័យថាវ៉ាក់សាំងទាំងនេះគ្មានសុវត្ថិភាពនោះទេ។

ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រដ៏គួរឲ្យកត់សម្គាល់រាប់ទសវត្សរ៍តាំងពីមុនពេលមានជំងឺរាតត្បាតនេះបន្ថែមពីលើកិច្ចសហការក្នុងចំណោមអ្នកវិទ្យាសាស្ត្រនៅជុំវិញពិភពលោក ធ្វើឲ្យការផលិតបានយ៉ាងឆាប់រហ័សអាចទៅរួច។

## ការពិតទី #3

### វ៉ាក់សាំងជំងឺ COVID-19 អាចនឹងផ្តល់ការការពារប្រឆាំងនឹងប្រភេទវីរុសលើសពីមួយ។

ដូចវីរុសទាំងអស់ដែរ វីរុស SARS-CoV-2 (វីរុសដែលបង្កជំងឺ COVID-19) បង្កើតការបំប្លែងខ្លួនតិចតួចទៅតាមពេលវេលា។ ព័ត៌មានរហូតមកដល់ពេលបច្ចុប្បន្ននេះបង្ហាញថាវ៉ាក់សាំងជំងឺ COVID-19 ឈ្មោះ Pfizer និង Moderna គឺមានប្រសិទ្ធភាពប្រឆាំងនឹងវីរុសច្រើនប្រភេទដែលកំពុងតែចរាចរ។

## ការពិតទី #4

### វ៉ាក់សាំងជំងឺ COVID-19 នឹងមិនកែប្រែ DNA របស់អ្នកទេ។

វ៉ាក់សាំង COVID-19 ប្រើប្រាស់ mRNA ដែលមិនកែប្រែ DNA របស់អ្នកតាមមធ្យោបាយណាមួយបាននោះទេ។ វាធ្វើឲ្យមានការឆ្លើយតបភាពស៊ាំដែលបង្កើតអង្គបដិបក្ខប្រាណដែលការពារអ្នកពីការឆ្លងជំងឺ។

## ការពិតទី #5

### វ៉ាក់សាំងជំងឺ COVID-19 មិនមានជាប់ពាក់ព័ន្ធទៅនឹងការមិនអាចបង្កកំណើតបាន ឬការរលូតនោះទេ។

មិនមានភស្តុតាងបង្ហាញថាវ៉ាក់សាំងជំងឺ COVID-19 បង្កឲ្យមានការមិនអាចបង្កកំណើតបាន ឬបង្កើនឱកាសនៃការរលូតរបស់អ្នកនោះទេ។ លើសពីនោះទៅទៀត ការឆ្លើយតបភាពស៊ាំដោយធម្មជាតិក្រោយពេលឆ្លងទៅនឹងជំងឺ COVID-19 ដែលវ៉ាក់សាំងធ្វើត្រាប់តាម មិនបណ្តាលឲ្យមានការកើនឡើងនូវការរលូត ឬការមិនអាចបង្កកំណើតបាននោះទេ។

## ការពិតទី #6

### យើងដឹងច្បាស់ថាមានអ្វីនៅក្នុងវ៉ាក់សាំងជំងឺ COVID-19។

វ៉ាក់សាំង Pfizer និង Moderna បានចុះផ្សាយនូវតារាងសារធាតុផ្សំនៃវ៉ាក់សាំងជំងឺ COVID-19 រួចហើយ។ ការប៉ាន់ស្មានដែលថាមានផ្ទុកបន្ទះមីក្រូឈីប ឬឧបករណ៍តាមដាន ត្រូវបានបញ្ជាក់ថាមិនពិតនោះទេ។

GET THE FACTS ON THE VAX


ប្រភព

- www.cdc.gov/vaccines/index.html